វេទិកាកសិករថ្នាក់ជាតិ លើកទី១២ ស្តីពី
សុវត្ថិភាពចំណីអាហារ និងពិព័រណ៍ចំណេះដឹង

12th National Farmer Forum "Food Security and Knowledge Fair"

សហការរៀបចំដោយ Co-organized by

# សេចក្តីប្រកាសព័ត៌មាន

## "ដល់ពេលដែលយើងត្រូវគិតគូរអំពីសុវត្ថិភាពចំណីអាហារ"

មានជម្ងឺ **៦០០លានករណី** និងមនុស្សប្រមាណ**៤២០ពាន់នាក់** ត្រូវបានបាត់បង់ជីវិតនៅទូទាំងសកលលោកជារៀងរាល់ឆ្នាំ ដោយសារតែបញ្ហាអាហារគ្មានសុវត្ថិភាព។ ម៉្យាងវិញទៀត អត្រាមរណៈភាពកុមារអាយុក្រោម៥ឆ្នាំមានប្រមាណ៤០% បង្កឡើងដោយម្ហូបអាហារគ្មានសុវត្ថិភាព នេះបើតាម អង្គការស្បៀងនិង កសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា(FAO)។ បញ្ហានេះបានរារាំង កំណើនសេដ្ឋកិច្ច និងការបាត់បង់ផលិតភាពប្រចាំឆ្នាំរហូតដល់ ៩៥ពាន់លានដុល្លានៅក្នុងប្រទេស ដែលមានចំណូលទាប និងមធ្យម។

សុវត្ថិភាពចំណីអាហារគឺជាប្រធានបទរួម ដែលត្រូវបានជ្រើសរើសយកមកជជែកពិភាក្សា ចែករំលែកក្នុងចំណោម រាជរដ្ឋាភិបាល សហគមន៍កសិកម្ម កសិករ យុវជន យុវនារី អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាកសិករលើកទី១២ និងការតាំងពិព័រណ៍ចំណេះដឹង ដែលប្រព្រឹត្តទៅនៅថ្ងៃទី ៦-៧ ខែធ្នូ ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលជាយកូនៀរាជធានីភ្នំពេញ។

លទ្ធផលរំពឹងទុក៣សំខាន់ៗ ដែលវេទិកាកសិករលើកទី១២ គ្រោងសម្រេចបានគឺ ១) អ្នកពាក់ព័ន្ធ និងកសិករបានយល់យ៉ាងច្បាស់អំពីស្តង់ដារសុវត្ថិភាពចំណីអាហារ គោលការណ៍ណែនាំ គោលការណ៍ និងច្បាប់នៅកម្ពុជា, ២) ភាគីពាក់ព័ន្ធ និងកសិករបានចែករំលែក និងសិក្សាពីការអនុវត្តល្អៗជាច្រើនអំពីសុវត្ថិភាពចំណីអាហារនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្មនីមួយៗ ដែលអនុវត្តដោយបុគ្គល និងសហករណ៍កសិកម្ម, ៣) ចងក្រងឲ្យមានឯកសារស្តីពីការអនុវត្តល្អនៅក្នុងខ្សែច្រវាក់តម្លៃនីមួយៗសម្រាប់ការលើកកម្ពស់សុវត្ថិភាពម្ហូបអាហារប្រកបដោយនិរន្តរភាពនៅកម្ពុជា។

**លោក សឿង សារឿន** នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានលើកឡើងថា "ដើម្បីលើកកម្ពស់សុវត្ថិភាពចំណីអាហារ យើងត្រូវពិចារណានិងធ្វើសកម្មភាពជាដៃគូរគ្រប់ភាគី និងគ្រប់កម្រិត លើដំណើរការតាក់តែងច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ការកៀរគរធនធាន ការអនុវត្ត និងការត្រួតពិនិត្យ នៃចំណុចពាក់ព័ន្ធសំខាន់ៗ រួមមាន ទឹក ទុន ទីតាំងផលិត ទីផ្សារ និងទទួលទាន ឬ អាចនិយាយបានថា ផលិតកម្មដែលរាប់ពីធាតុចូលផលិតកម្ម ការប្រមូលផល ការស្តុក ថែរក្សា ការកែឆ្នៃវេចខ្ចប់ ទីផ្សារ រហូតមកដល់ផ្ទះបាយ និងទទួលទាន។"

សុវត្ថិភាពចំណីអាហារ គឺមានសារៈសំខាន់ណាស់ ចំពោះការរស់នៅប្រចាំថ្ងៃរបស់យើងទាំងអស់គ្នា។ តើត្រូវធ្វើដូចម្តេចដើម្បីឲ្យយើងដឹងថាចំណីអាហារមានសុវត្ថិភាព? **លោកស្រី ង៉ិន ណាវីរៈ** មន្ត្រីជាតិសម្របសម្រួលកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោករបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានពន្យល់ថា "សុវត្ថិភាពចំណីអាហារ គឺជាចំណីដែលយើងញ៉ាំទៅមិនឈឺពោះ និងមិនមានផលប៉ះពាល់ដល់សុខភាពទៅថ្ងៃក្រោយ។" លោកស្រីបន្ថែមថា អ្នកផលិតពូជ (សត្វ ដំណាំ) អ្នកដាំដុះ អ្នកប្រមូលទិញ អ្នកកែឆ្នៃផលិតម្ហូបអាហារ អ្នកដឹកជញ្ជូន អ្នកលក់ និងអ្នកបរិភោគ អ្នករៀបចំគោលនយោបាយ អ្នកត្រួតពិនិត្យម្ហូបអាហារ និងអ្នកថែរក្សា ឬស្តុកម្ហូបអាហារ ជាអ្នកទទួលខុសត្រូវលើចំណីអាហារដែលយើងផលិត និងបរិភោគ។

ថ្លែងក្នុងឱកាសបើកវេទិកាកសិករថ្នាក់ជាតិលើកទី១២ **«សុវត្ថិភាព ចំណីអាហារ និងពិព័រណ៍ចំណេះដឹង» ឯកឧត្តម ព្រាប កុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា"**វិស័យកសិកម្មក្នុងនោះរួមមានសុវត្ថិភាពចំណីអាហារក្នុងច្រវាក់ផលិតកម្មគឺជាអាទិភាពខ្ពស់មួយក្នុងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអាណត្តិទីប្រាំពីរ ក្នុងគោលដៅជម្រុញផលិតកម្មកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាពដែលអាចប្រកួតប្រជែងក្នុងទីផ្សារជាតិនិងអន្តរជាតិដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យមានសន្ទុះយ៉ាងលឿនសំដៅឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋខ្មែរនិងដើម្បីឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលអភិវឌ្ឍន៍កម្ពុជាឲ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ "។**

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តម ព្រាប កុល** បានស្វាគមន៍ចំពោះការចូលរួមចំណែកគាំទ្រយ៉ាងសកម្មរបស់គូរអង្គពាក់ព័ន្ធទាំងអស់រួមមាន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន សាជីវកម្ម សហគមន៍ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ក្នុងបំណងរួមចំណែកដោះស្រាយបញ្ហាខាងលើ តាមរយៈកិច្ចសហការល្អជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជា សេនាធិការរបស់រាជរដ្ឋាភិបាល និងជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីជំនាញ និងក្រុមជនបង្គោល ការអប់រំផ្សព្វផ្សាយ សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងកិច្ចពិភាក្សាពហុភាគី រួមទាំងការការផ្តល់ធាតុចូលសម្រាប់ជាជំនួយដល់ការរៀបចំ និងតាក់តែងនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការអនុវត្តឲ្យកាន់តែមានគុណភាព និងប្រសិទ្ធិភាពថែមមួយកម្រិតទៀត»។